ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អាជ្ញាធរអគ្គិសនីកម្ពុជា

# បទប្បញ្ញត្តិ

## ស្តីពីគោលការណ៍ទូទៅសម្រាប់កំណត់
## បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

អនុម័តដោយសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី ១១៣
នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៧

# សេចក្តីសម្រេច
# ស្តីពីគោលការណ៍ទូទៅសម្រាប់កំណត់
# បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## អាជ្ញាធរអគ្គិសនីកម្ពុជា

–អនុវត្តតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១

–អនុវត្តតាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១០៤/០២២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ទី នរិទ្ធ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា

– –យោងតាមការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធអ្នកកាន់អាជ្ញាប័ណ្ណ និងសាធារណជនដែលធ្វើឡើងចាប់ពីថ្ងៃ ២៥ ខែឧសភា ឆ្នាំ២០០៧ ដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៧

– –យោងតាមការអនុម័តរបស់សម័យប្រជុំលើកទី១១៣ របស់អាជ្ញាធរអគ្គិសនីកម្ពុជានៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៧

## សម្រេច

**ប្រការ១.–**

ចេញនូវបទប្បញ្ញត្តិមួយមានឈ្មោះថា "បទប្បញ្ញត្តិស្តីពីគោលការណ៍ទូទៅ សម្រាប់កំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា" អនុលោមតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់គ្រប់គ្រងដំណើរការការពិនិត្យថ្លៃលក់ឡើងវិញ និងការកំណត់ថ្លៃលក់អគ្គិសនី ដើម្បីធានាឱ្យមានភាពត្រឹមត្រូវ និងរក្សាតុល្យភាពរវាងផលប្រយោជន៍របស់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.–**

បទប្បញ្ញត្តិនេះមានខ្លឹមសារទាំងស្រុងដូចអត្ថបទដែលភ្ជាប់មកជាមួយ។

**ប្រការ៣.–**

បទប្បញ្ញត្តិនេះមានប្រសិទ្ធភាពអនុវត្តចំពោះរាល់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អ្នកកាន់អាជ្ញាប័ណ្ណលក់រាយ អ្នកកាន់អាជ្ញាប័ណ្ណរួម(ដែលមានការធ្វើ សេវាកម្មចែកចាយ ឬការធ្វើសេវាកម្មលក់រាយ) និងចំពោះអ្នកប្រើប្រាស់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងការផ្គត់ផ្គង់ ការទទួល និងការប្រើប្រាស់អគ្គិសនី។

**ប្រការ៤.-**

បទប្បញ្ញត្តិនេះ ត្រូវចូលជាធរមានសម្រាប់អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅរហូតដល់មានការសម្រេចជាថ្មី ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកែសម្រួលនិង ចេញបទប្បញ្ញត្តិនេះឡើងវិញ នៅគ្រប់ពេល ។

**ប្រការ៥.-**

លេខាធិការដ្ឋាននៃអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវផ្សព្វផ្សាយបទប្បញ្ញត្តិនេះជា សាធារណៈ ។

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## តារាងមាតិកា

### ជំពូកទី១: បទប្បញ្ញត្តិទូទៅ


១.១ គោលបំណង

១.២ ឈ្មោះ

១.៣ យុត្តាធិការ

១.៤ ភាពត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ និងច្បាប់ផ្សេងៗ

១.៥ សិទ្ធិអំណាចក្នុងការកែសម្រួលបទប្បញ្ញត្តិ

១.៦ សិទ្ធិក្នុងការលុបចោលការលំបាក

១.៧ និយមន័យ


### ជំពូកទី២: ការកំណត់របស់ច្បាប់ស្តីពីអគ្គិសនី


២.១ សិទ្ធិអំណាចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការពិនិត្យនិងក្នុងការ អនុម័តបញ្ជីថ្លៃលក់អគ្គិសនី

២.២ គោលបំណងរបស់បញ្ជីថ្លៃលក់អគ្គិសនី

២.៣ នីតិវិធីសម្រាប់ពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ

២.៤ វិធាននានាសម្រាប់ពិភាក្សាថ្លៃលក់អគ្គិសនី


### ជំពូកទី៣: គោលការណ៍របស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកំណត់ បញ្ជីថ្លៃលក់អគ្គិសនី


៣.១ គោលការណ៍ទូទៅ

៣.២ វិធីសាស្រ្តសម្រាប់កំណត់បញ្ជីថ្លៃលក់របស់អគ្គិសនីកម្ពុជា និងរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ

៣.៣ វិធីសាស្រ្តកំណត់ថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណធ្វើ សេវាកម្មធុនតូច


### ជំពូកទី៤: ការពិនិត្យ និងអនុម័តថ្លៃលក់អគ្គិសនី


៤.១ ការត្រួតពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីប្រចាំឆ្នាំ

៤.២ ការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីតាមសំណើរបស់អ្នកកាន់អាជ្ញាប័ណ្ណ

៤.៣ ការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណថ្មី

៤.៤ កាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណទាក់ទងនឹងការពិនិត្យបញ្ជីថ្លៃលក់


### ជំពូកទី៥: ការវាយតម្លៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ


៥.១ ចំណាយត្រឹមត្រូវ

៥.២ ការកំណត់ដោយឡែកសម្រាប់អាជីវកម្មផ្សេងៗគ្នា

៥.៣ វិធីសាស្ត្រទូទៅសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកផលិតកម្ម
៥.៤ វិធីសាស្ត្រទូទៅសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកបញ្ជូន
៥.៥ វិធីសាស្ត្រទូទៅសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកចែកចាយ
៥.៦ គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយដំណើរការនិងការថែទាំ
៥.៧ គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយលើប្រេងឥន្ធនៈ
៥.៨ គោលការណ៍កំណត់ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ
៥.៩ គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយទិញអគ្គិសនី
៥.១០ គោលការណ៍កំណត់តម្លៃត្រឹមត្រូវនៃអចលនទ្រព្យ
៥.១១ គោលការណ៍កំណត់ចំណាយលើការជួល
៥.១២ គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយសម្រាប់រំលោះ
៥.១៣ គោលការណ៍កំណត់អត្រាប្រាក់ចំណេញសមស្របនិងចំណាយប្រើប្រាស់ឥណទាន
៥.១៤ គោលការណ៍កំណត់ថាមពលលក់ និងចំណូល
៥.១៥ គោលការណ៍កំណត់ថាមពលបាត់បង់

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

## ១.១. គោលបំណង

អនុវត្តតាមមាត្រា៧ មាត្រា៤៦ មាត្រា៤៧ និងមាត្រា៤៨ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ អាជ្ញាធរអគ្គិសនីកម្ពុជា រៀបចំបទប្បញ្ញត្តិស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម។ គោលបំណងនៃបទប្បញ្ញត្តិនេះគឺដើម្បីធានាថានៅក្នុងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ផលប្រយោជន៍របស់អ្នកកាន់អាជ្ញាប័ណ្ណនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវមានតុល្យភាពទៅវិញទៅមកហើយគោលបំណងរបស់ច្បាប់ក៏ត្រូវបានបំពេញផងដែរ។ បទប្បញ្ញត្តិនេះរួមមានគោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា កាតព្វកិច្ចផ្តល់ទិន្នន័យហិរញ្ញវត្ថុ និងពត៌មានផ្សេងៗរបស់អ្នកកាន់អាជ្ញាប័ណ្ណព្រមទាំងវិធីសាស្ត្រ និងដំណើរការដែលអាជ្ញាធរត្រូវអនុវត្តក្នុងការពិនិត្យនិងកំណត់បញ្ជីថ្លៃលក់អគ្គិសនី។

## ១.២. ឈ្មោះ

បទប្បញ្ញត្តិនេះមានឈ្មោះថា **“បទប្បញ្ញត្តិស្តីពីគោលការណ៍ទូទៅសម្រាប់កំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា”**។

## ១.៣_ យុត្តាធិការ

បទប្បញ្ញត្តិនេះ ត្រូវអនុវត្តចំពោះរាល់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អ្នកកាន់ អាជ្ញាប័ណ្ណលក់រាយ អ្នកកាន់អាជ្ញាប័ណ្ណរួម (ដែលមានការធ្វើសេវាកម្ម ចែកចាយ ឬការធ្វើសេវាកម្មលក់រាយ) និងចំពោះអ្នកប្រើប្រាស់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងការផ្គត់ផ្គង់ ការទទួល និង ការប្រើប្រាស់អគ្គិសនី។

## ១.៤_ ភាពត្រឹមត្រូវតាមច្បាប់ស្ដីពីអគ្គិសនី អនុក្រឹត្យ និង ច្បាប់ផ្សេងៗ

១. បទប្បញ្ញត្តិនេះ រៀបចំឡើងដោយអនុលោមតាមច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជានិងស្របតាមអនុក្រឹត្យស្ដីពីគោលការណ៍ការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី។បទប្បញ្ញត្តិនេះទាក់ទងនឹងសិទ្ធិអំណាចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនី។ បទប្បញ្ញត្តិនេះមានទំនាក់ទំនងជាមួយនីតិវិធីនានា និងបទប្បញ្ញត្តិផ្សេងៗ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញជាបន្តបន្ទាប់។

២. ដើម្បីបំពេញកាតព្វកិច្ចតាមច្បាប់បទប្បញ្ញត្តិនេះទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណរក្សាទុកទិន្នន័យគណនេយ្យនិងពត៌មានផ្សេងៗ សម្រាប់ផ្ដល់ទិន្នន័យ ទាំងនោះឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា។ បទប្បញ្ញត្តិនេះមិនអាចលុបឬកែសម្រួលកាតព្វកិច្ចផ្សេងៗរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងការរក្សាទុក និងផ្ដល់ទិន្នន័យហិរញ្ញវត្ថុឱ្យស្ថាប័នផ្សេងៗ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដ៏ទៃទៀតនោះទេ។

៣. ត្រូវបែងចែកឱ្យដាច់ពីគ្នានូវទិន្នន័យដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ដល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា និងទិន្នន័យគណនេយ្យសម្រាប់ការធ្វើសវនកម្ម ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំជាប្រចាំសម្រាប់សវនករ។ ពត៌មានមួយចំនួនដែលទាមទារក្នុងដំណើរការកំណត់បញ្ជីថ្លៃលក់អគ្គិសនីមាន ទម្រង់និងលក្ខណៈខុសគ្នាពីពត៌មាន ដែលអ្នកកាន់អាជ្ញាប័ណ្ណរៀបចំទៅតាមស្តង់ដារគណនេយ្យ។ ការកត់ត្រានិងរបាយការណ៍តាមស្តង់ដារគណនេយ្យ គឺផ្ដល់ពត៌មានមូលដ្ឋានអំពីចំណូល ចំណាយ ប្រាក់ចំណេញឬ ខាតទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនប៉ុណ្ណោះ។គោលបំណងធ្វើសវនកម្មគឺត្រួតពិនិត្យរកភាពត្រឹមត្រូវនៃការអនុវត្តន៍តាមស្តង់ដារគណនេយ្យ។ ម្យ៉ាងទៀតគោលបំណងនៃទិន្នន័យដែលទាមទារដោយអាជ្ញាធរអគ្គិសនីកម្ពុជា គឺដើម្បីពិនិត្យផ្ទៀងផ្ទាត់រកភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយធ្វើការវិភាគអំពីចំណូលពីការលក់ និងពិនិត្យមើលកម្រិតប្រសិទ្ធភាព និងធានាតុល្យភាពគ្នារវាង ផលប្រយោជន៍របស់អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់។ ដូច្នេះទិន្នន័យដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការអាចខុសពីទិន្នន័យនិងទម្រង់របស់ស្តង់ដារគណនេយ្យ។

## ១.៥_ សិទ្ធិអំណាចក្នុងការកែសម្រួលបទប្បញ្ញត្តិ

អាជ្ញាធរអគ្គិសនីកម្ពុជាអាចកែសម្រួលនិងចេញបទប្បញ្ញត្តិនេះឡើងវិញនៅគ្រប់ពេល។

## ១.៦_ សិទ្ធិក្នុងការលុបចោលការលំបាក

ប្រសិនបើមានការលំបាកណាមួយកើតឡើងដោយសារតែបញ្ញត្តិណាមួយនៃបទប្បញ្ញត្តិនេះអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញបញ្ញត្តិមួយទៀតដែលមិនផ្ទុយពីខ្លឹមសាររបស់ច្បាប់ (ដោយសេចក្ដីសម្រេចជាទូទៅ ឬ សេចក្ដីសម្រេចពិសេសណាមួយ) ដែលបញ្ញត្តិនេះគឺជាការចាំបាច់ដើម្បីលុបចោលការលំបាកដែលកើតឡើងនេះ។

## ១.៧_និយមន័យ

ក្នុងបទប្បញ្ញត្តិ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេពាក្យខាងក្រោមនេះ ត្រូវមានន័យដូចខាងក្រោម :

**"អ.អ.ក"** មានន័យថា អាជ្ញាធរអគ្គិសនីកម្ពុជា ដែលបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**"អ.ក"** មានន័យថា ក្រុមហ៊ុនអគ្គិសនីកម្ពុជារួមទាំងសាខានានានៅកម្ពុជា

**"ច្បាប់"** មានន័យថា ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១

**"អាជ្ញាប័ណ្ណ"** មានន័យថា អាជ្ញាប័ណ្ណណាមួយដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមច្បាប់ដែលបទប្បញ្ញត្តិនេះត្រូវអនុវត្តតាម ។

**"អ្នកកាន់អាជ្ញាប័ណ្ណ"** មានន័យថាអ្នកកាន់អាជ្ញាប័ណ្ណណាមួយដែលបទប្បញ្ញត្តិនេះត្រូវអនុវត្តចំពោះ ។

**"នីតិវិធី"** មានន័យថា នីតិវិធីសម្រាប់ការតាមដានទិន្នន័យការដាក់ពាក្យស្នើសុំការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលអនុលោមតាមច្បាប់ស្តីពីអគ្គិសនី ។

**"បទប្បញ្ញត្តិ"** មានន័យថា បទប្បញ្ញត្តិនេះ

**"អនុក្រឹត្យ"** មានន័យថា អនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនីអនុលោមតាមច្បាប់ស្តីពីអគ្គិសនី ។

# ជំពូកទី ២
# ការកំណត់របស់ច្បាប់ស្តីពីអគ្គិសនី

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាមានបញ្ញត្តិមួយចំនួនថែងអំពីបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានយកមកជាមូលដ្ឋានក្នុងការរៀបចំបទប្បញ្ញត្តិនេះ ។ បញ្ញត្តិរបស់ច្បាប់ទាំងនេះមានដូចខាងក្រោម :

## ២.១_សិទ្ធិអំណាចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការពិនិត្យ និងក្នុងការអនុម័តបញ្ជីថ្លៃលក់អគ្គិសនី

មាត្រា៧ នៃច្បាប់ស្តីពីអគ្គិសនីផ្តល់សិទ្ធិឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាអនុម័តថ្លៃ និងបន្ទុកចំណាយផ្សេងៗព្រមទាំងល័ក្ខខ័ណ្ឌនៃសេវាកម្មអគ្គិសនីរបស់ អ្នកកាន់អាជ្ញាប័ណ្ណ លើកលែងតែអាជ្ញាធរយល់ថាថ្លៃនិងបន្ទុកចំណាយផ្សេងៗ ព្រមទាំងល័ក្ខខ័ណ្ឌទាំងនោះត្រូវបានបង្កើតឡើងតាមវិធីប្រកួតប្រជែងដោយផ្អែកលើទីផ្សារពិតប្រាកដ ។ អនុលោមតាមមាត្រា៤៦នៃច្បាប់អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុម័ត ឬកែសម្រួលបញ្ជីថ្លៃលក់របស់អ្នកកាន់ អាជ្ញាប័ណ្ណទៅតាម ១-ពាក្យស្នើសុំរបស់អ្នកកាន់អាជ្ញាប័ណ្ណ ឬ២-ការពិនិត្យដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

## ២.២_គោលបំណងរបស់បញ្ជីថ្លៃលក់អគ្គិសនី

មាត្រា៤៨ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ល័ក្ខខ័ណ្ឌសម្រាប់បញ្ជីថ្លៃលក់ថាបញ្ជីថ្លៃលក់អគ្គិសនីដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែ :

១- ការពារអ្នកប្រើប្រាស់ទល់នឹងការកំណត់ថ្លៃផ្តាច់មុខ

២- ផ្តល់លទ្ធភាពឱ្យអ្នកកាន់អាជ្ញាប័ណ្ណអាចរំលោះចំណាយរបស់គេប៉ុន្តែចំណាយនេះត្រូវជាចំណាយត្រឹមត្រូវតាមគោលការណ៍នៃការធ្វើអាជីវកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ

៣- លើកទឹកចិត្តចំពោះប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការនិងការគ្រប់គ្រងផ្ទៃក្នុងរបស់អ្នកកាន់អាជ្ញាប័ណ្ណដោយអនុញ្ញាតឱ្យបង្កើនចំណូលហិរញ្ញវត្ថុស្របតាមការបន្ថយចំណាយក្នុងការផ្តល់សេវាកម្មឱ្យតែអ្នកកាន់អាជ្ញាប័ណ្ណនោះបានធានាការផ្គត់ផ្គង់និង គុណភាពសេវា តាមការតម្រូវនៃអាជ្ញាប័ណ្ណរបស់ខ្លួន

៤- លើកទឹកចិត្តចំពោះប្រសិទ្ធភាពសេដ្ឋកិច្ចក្នុងវិស័យអគ្គិសនីដោយឆ្លុះបញ្ចាំងអំពីចំណាយម៉ាហ្ស៊ីណាល់សម្រាប់រយៈពេលខ្លីនិងរយៈពេល វែង និងដោយចង្អុលបង្ហាញថ្លៃពិតប្រាកដ យោងទៅតាមភាពបរិបូរណ៍ឬកង្វះក្នុងការផ្គត់ផ្គង់សេវាកម្មអគ្គិសនី

៥- គិតដល់ចំណាយនិងភាពខុសគ្នាជាក់ស្តែងរវាងប្រភេទអ្នកជាវនិងប្រភេទសេវានិងដល់ការបំពេញខាតណាមួយដែលរាជរដ្ឋាភិបាលផ្តល់ឱ្យសម្រាប់ឧបត្ថម្ភអ្នកជាវ ឬប្រភេទនៃអ្នកជាវណាមួយ ។

## ២.៣_នីតិវិធីសម្រាប់ការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ

ដើម្បីសម្រួលដំណើរការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងកំណត់បញ្ជីថ្លៃលក់ ឬកែសម្រួលបញ្ជីថ្លៃលក់របស់អ្នកកាន់អាជ្ញាប័ណ្ណទោះជាតាម ១-ពាក្យស្នើសុំកែសម្រួលថ្លៃលក់របស់អ្នកកាន់អាជ្ញាប័ណ្ណ ឬការពិនិត្យឡើងវិញដោយអាជ្ញាធរអគ្គិសនីកម្ពុជាក៏ដោយមាត្រា៤៧ចែងថា អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបង្កើតបែបបទនិងគំរូសម្រាប់អនុវត្តការដាក់ពាក្យស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនីដោយអនុលោមតាមបញ្ញត្តិនៃច្បាប់ដែលរួមមាន :

(ក) ការតម្រូវជាក់ស្តែងសម្រាប់ការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនីដោយរាប់បញ្ចូលទាំងពត៌មានហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មរួចហើយ

(ខ) រយៈពេលសម្រាប់ការស្នើសុំអនុម័តនិងសេចក្តីសម្រេចបញ្ជីថ្លៃលក់អគ្គិសនី

(គ) នីតិវិធីសម្រាប់អ្នកប្រើប្រាស់និងភាគីដែលពាក់ព័ន្ធផ្សេងទៀតដើម្បីផ្តល់មតិលើការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនីនិង

(ឃ) នីតិវិធីសម្រាប់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការទទួលពត៌មានបន្ថែមចាំបាច់ពីអ្នកដាក់ពាក្យសុំសម្រាប់វាយតំលៃលើការស្នើសុំអនុម័តបញ្ជីថ្លៃលក់អគ្គិសនី ។

មាត្រា៤៦ នៃច្បាប់ស្តីពីអគ្គិសនីចែងថា អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុម័ត និងកែសម្រួលថ្លៃបន្ទុកចំណាយផ្សេងៗល័ក្ខខ័ណ្ឌធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណហើយក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំរបស់អ្នកកាន់អាជ្ញាប័ណ្ណអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវ អនុម័តកែប្រែឬបដិសេធចោលសំណើដែលស្នើសុំកំណត់ ឬសុំផ្លាស់ប្តូរបញ្ជីថ្លៃលក់នោះ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់ថ្ងៃចូលជាធរមាននៃ បញ្ជីថ្លៃលក់អគ្គិសនីថ្មីឬថ្ងៃកែសម្រួលឡើងវិញដែលមិនត្រូវឱ្យហួសរយៈពេល ៩០(កៅសិប)ថ្ងៃដូចបានកំណត់ខាងលើ។

## ២.៤_វិធាននានាសម្រាប់ការពិភាក្សាលើបញ្ជីថ្លៃលក់អគ្គិសនី

ដើម្បីធានាឱ្យមានតម្លាភាពក្នុងការពិនិត្យថ្លៃលក់អគ្គិសនីក្នុងការអនុវត្តមុខងាររបស់ខ្លួនស្របតាមបទប្បញ្ញត្តិនេះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុវត្ត តាមវិធានសម្រាប់គ្រប់គ្រងការប្រជុំដែលមានចែងក្នុងមាត្រា២០នៃច្បាប់អគ្គិសនី ។

វិធាននេះគ្រប់គ្រងការប្រជុំរវាងសមាជិកឬមន្ត្រីអាជ្ញាធរអគ្គិសនីកម្ពុជាជាមួយភាគីណាមួយដែលទាក់ទងនឹងការកសាងបញ្ជីថ្លៃលក់នោះ។ វិធាននេះត្រូវកំណត់អំពីកម្មវត្ថុកាលបរិច្ឆេទទីកន្លែង និងដំណើរការនៃការប្រជុំសំដៅផ្តល់លទ្ធភាពឱ្យភាគីពាក់ព័ន្ធអាចចូលរួមប្រជុំបាន។

## ជំពូកទី ៣
## គោលការណ៍របស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី

### ៣.១~ គោលការណ៍ទូទៅ

១. អាជ្ញាធរអគ្គិសនីកម្ពុជានឹងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណណាដែលពិនិត្យឃើញថាបញ្ជីថ្លៃលក់នោះបំពេញបាននូវគោលបំណងរបស់ ច្បាប់។ នៅក្នុងការកំណត់បញ្ជីថ្លៃលក់បែបនោះអាជ្ញាធរអគ្គិសនីកម្ពុជា នឹងអនុវត្តតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹត្យនិងបទប្បញ្ញត្តិនេះ (លើកលែងតែក្នុងករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យឃើញថាបើអនុវត្តដូច្នេះវាមិនត្រឹមត្រូវទៅតាមស្ថានភាព)។

២. អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថាបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណអាចរំលោះកម្រិតចំណាយត្រឹមត្រូវរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដោយដកប្រាក់ឧបត្ថម្ភធនជាចំណូលណាមួយ និងចំណូលផ្សេងទៀតដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលពីអាជីវកម្មរបស់ខ្លួន។នៅក្នុងកាលៈទេសៈពិសេសប្រសិនបើអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចរក្សាទុកកម្រិតលំអៀង នៃចំណូលដែលខ្វះសម្រាប់បំពេញឱ្យចំណាយត្រឹមត្រូវសរុបនោះអាជ្ញាធរអាចធ្វើការកែតម្រូវដោយផ្អែកលើការវិភាគចំណាយត្រឹមត្រូវដើម្បីប៉ះប៉ូវកម្រិតលំអៀងនៃចំណូលនេះនៅពេលខាងមុខបាន។

៣. នៅកន្លែងណាដែលចំណូលពីបញ្ជីថ្លៃលក់បច្ចុប្បន្នឬពីបញ្ជីថ្លៃលក់ស្នើសុំទទួលបានទាបជាងកម្រិតចំណាយត្រឹមត្រូវដែលឆ្លុះបញ្ចាំងថាត្រូវមានការបំពេញខាតណាមួយនោះអាជ្ញាធរអគ្គិសនីកម្ពុជាអាចទទួលយកបាន ប្រសិនបើការបំពេញខាតនោះស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលហើយអ្នកកាន់អាជ្ញាប័ណ្ណពិតជាទទួលបាននូវការបំពេញខាតទាំងស្រុងពីស្ថាប័នផ្តល់ឧបត្ថម្ភធននៅពេលនោះពិតប្រាកដមែន។

៤. នៅពេលដែលបញ្ជីថ្លៃលក់បច្ចុប្បន្នឬបញ្ជីថ្លៃលក់ស្នើសុំកំណត់ឡើងវិញដោយមានការបំពេញខាតក្នុងចំណោមអ្នកប្រើប្រាស់ឬក្រុមអ្នកប្រើប្រាស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវទទួលយក ប្រសិនបើការបំពេញខាតនោះស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងត្រូវបានគិតគូរត្រឹមត្រូវតាមគ្រប់ស្ថានភាព។

៥. អាជ្ញាធរអគ្គិសនីកម្ពុជាចង់បានការធានាថា ប្រសិនបើមានការរៀបចំឱ្យមានការបំពេញខាតណាមួយនោះរចនាសម្ព័ន្ធបញ្ជីថ្លៃលក់បច្ចុប្បន្នឬបញ្ជីថ្លៃលក់ស្នើសុំត្រូវបំពេញបានគោលបំណងដូចខាងក្រោម និងសង្ឃឹមថាអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ការសិក្សាថ្លៃដើមឬការសិក្សាផ្សេងៗដែលបង្ហាញឱ្យឃើញថា:

(ក) ចំណូលដែលប្រមូលបានពីអ្នកប្រើប្រាស់តាមប្រភេទផ្សេងៗគ្នាឆ្លុះបញ្ចាំងនូវបន្ទុកចំណាយសេវាផ្គត់ផ្គង់ដែល ពួកគេបានទទួល។

(ខ) រចនាសម្ព័ន្ធបញ្ជីថ្លៃលក់សម្រាប់ក្នុងប្រភេទអ្នកប្រើប្រាស់ និងរវាងប្រភេទនីមួយៗ ត្រូវឆ្លុះបញ្ចាំងពីចំណាយដែលប្រភេទអ្នកប្រើប្រាស់ទាំងនោះបានទទួល។

៦. នៅកន្លែងណាដែលយល់ថាចាំបាច់អាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ចូលនូវយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងឥន្ធនៈក្នុងរចនាសម្ព័ន្ធបញ្ជីថ្លៃលក់។ យន្តការនេះអាចអនុញ្ញាតឱ្យធ្វើការកែតម្រូវលើបញ្ជីថ្លៃលក់ដើម្បីឆ្លុះបញ្ចាំងពីការប្រែប្រួលថ្លៃប្រេងឥន្ធនៈ ថ្លៃទិញថាមពលអគ្គិសនី ។ល។

៧. បញ្ជីថ្លៃលក់អគ្គិសនីដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលមានកំណត់នៅក្នុងសេចក្តីសម្រេច និងត្រូវនៅជាធរមាន ប្រសិនបើគ្មានការកែសម្រួល ឬដកហូតទេ។ គ្មានបញ្ជីថ្លៃលក់អគ្គិសនីឬផ្នែកនៃបញ្ជីថ្លៃលក់ណាមួយអាចត្រូវបានកែសម្រួលឡើយលើកលែងតែ ការប្រែប្រួលណាមួយដែលមានបញ្ជាក់នៅក្នុងល័ក្ខខ័ណ្ឌនៃរូបមន្តកែសម្រួលថ្លៃលក់តាមថ្លៃប្រេងដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

៨. សម្រាប់គោលបំណងនៃការបញ្ញត្តិបញ្ជីថ្លៃលក់អគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការកំណត់អ្នកកាន់អាជ្ញាប័ណ្ណណាមួយថាជា “អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ” ឬ “អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច”។

## ៣.២.វិធីសាស្ត្រសម្រាប់កំណត់បញ្ជីថ្លៃលក់របស់អគ្គិសនីកម្ពុជា និងរបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ

១. ចំពោះករណីអគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណដទៃទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាចាត់ទុកថាជា “អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ” អ្នកកាន់អាជ្ញាប័ណ្ណទាំងនោះត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវទិន្នន័យប្រចាំឆ្នាំដែលមានទិន្នន័យគណនេយ្យ និងទិន្នន័យដទៃទៀត ហើយនីតិវិធីនិងល័ក្ខខ័ណសម្រាប់ការផ្តល់ទិន្នន័យនេះមានចែងនៅក្នុង “នីតិវិធីសម្រាប់ការតាមដានទិន្នន័យការដាក់ពាក្យស្នើសុំការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី”។ ដោយផ្អែកលើទិន្នន័យដែលទទួលបាននិង ទិន្នន័យដទៃទៀតអាជ្ញាធរអាចសម្រេចពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណមួយឬច្រើន។ អ្នកកាន់អាជ្ញាប័ណ្ណខ្លួនឯងអាចដាក់ពាក្យស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យបញ្ជីថ្លៃលក់របស់ខ្លួននៅពេលណាដែលពួកគេយល់ថាចាំបាច់។

២. ដោយសារមានល័ក្ខខ័ណ្ឌផ្សេងៗគ្នាចំពោះតំបន់ធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗគ្នាអាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់បញ្ជីថ្លៃលក់ អគ្គិសនីផ្សេងៗគ្នាចំពោះអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗគ្នានោះ។

៣. នៅក្នុងការពិនិត្យការផ្តល់ឯកសាររបស់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ និងនៅក្នុងការពិនិត្យបញ្ជីថ្លៃលក់អាជ្ញាធរនឹងពិនិត្យទាំងចំណាយត្រឹមត្រូវសរុប និងទាំងការឆ្លុះបញ្ចាំងនៃបញ្ជីថ្លៃលក់ទៅលើចំណាយត្រឹមត្រូវសរុបនេះ។

៤. ក្នុងការពិនិត្យភាពត្រឹមត្រូវនៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជានឹងខិតខំធ្វើការងារនេះដើម្បីធានាថាចំណាយទាំងនោះ គឺជាចំណាយត្រឹមត្រូវកើតឡើងពិតប្រាកដ និងចាំបាច់ចំពោះប្រតិបត្តិការអាជីវកម្មនិងស្របតាមអនុក្រឹត្យ។ ការប៉ាន់ស្មានចំណាយត្រឹមត្រូវរបស់អ្នកកាន់អាជ្ញាប័ណ្ណសម្រាប់ឆ្នាំបន្ទាប់ នឹងត្រូវពិនិត្យដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដោយអនុលោមតាមការកំណត់របស់អនុក្រឹត្យ និងត្រូវប្រើប្រាស់ក្នុងការវាយតម្លៃថាតើចាំបាច់ត្រូវធ្វើការកែសម្រួលបញ្ជីថ្លៃលក់ឬទេ។ ក្នុងការពិនិត្យភាពត្រឹមត្រូវនៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណអាជ្ញាធរអគ្គិសនីកម្ពុជានឹងអនុវត្តតាមបញ្ញត្តិនៃអនុក្រឹត្យ និងវិធីសាស្ត្រដែលមានចែងក្នុងបទប្បញ្ញត្តិនេះ។

## ៣.៣.វិធីសាស្ត្រកំណត់ថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនតូច

១. អ្នកកាន់អាជ្ញាប័ណ្ណធុនតូចទាំងអស់ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបញ្ជីគណនេយ្យ និងទិន្នន័យផ្សេងៗប្រចាំឆ្នាំ ហើយនីតិវិធីនិងល័ក្ខខ័ណ្ឌសម្រាប់ការផ្តល់ទិន្នន័យនេះមានកំណត់នៅក្នុង “នីតិវិធី”។ ផ្អែកលើទិន្នន័យនិងពត៌មានដែលបានទទួលអាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការវាយតម្លៃភាពត្រឹមត្រូវនៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណអនុលោម

តាមអនុក្រឹត្យ និងលើមូលដ្ឋានលទ្ធផលនៃការវាយតម្លៃនេះអាជ្ញាធរអគ្គិសនីកម្ពុជាអាចសម្រេចធ្វើការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញ។ អ្នកកាន់អាជ្ញាប័ណ្ណខ្លួនឯងក៏អាចស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីឡើងវិញបានដែរនៅពេលណាដែលខ្លួនយល់ថាចាំបាច់។

២. នៅក្នុងការពិនិត្យចំណាយត្រឹមត្រូវរបស់អ្នកកាន់អាជ្ញាប័ណ្ណមួយ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថា ចំណាយនោះរួមមានតែចំណាយដែលកើតឡើងជាក់ស្តែងពិតប្រាកដសម្រាប់ដំណើរការសកម្មភាពដែលមានក្នុងអាជ្ញាប័ណ្ណប៉ុណ្ណោះ។ អាជ្ញាធរនឹងប៉ាន់ស្មានចំណាយត្រឹមត្រូវសម្រាប់ឆ្នាំបន្ទាប់ និងវាយតម្លៃថាតើបញ្ជីថ្លៃលក់នោះចាំបាច់ត្រូវធ្វើការកែសម្រួលឬទេ។ នៅក្នុងការពិនិត្យចំណាយត្រឹមត្រូវរបស់អ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជានឹងអនុវត្តតាមការកំណត់របស់អនុក្រឹត្យ និងវិធីសាស្ត្រដែលមានចែងក្នុងបទប្បញ្ញត្តិនេះ។

៣. អាជ្ញាធរអគ្គិសនីកម្ពុជាអាចនឹងឈានទៅដល់ការចេញបញ្ជីថ្លៃលក់រួមមួយសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណជាក្រុម។ វិធីសាស្ត្រនេះទាមទារឱ្យមានការកំណត់អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មតូចៗជាក្រុមៗដែលមានលក្ខណៈប្រតិបត្តិការលក្ខណៈ បច្ចេកទេស ឬស្ថានភាពភូមិសាស្ត្រ ប្រហាក់ប្រហែលគ្នា។

# ជំពូកទី ៤
# ការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនី

## ៤.១.ការត្រួតពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីប្រចាំឆ្នាំ

១. អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវទិន្នន័យនិងពត៌មានផ្សេងៗទាក់ទងនឹងថ្លៃលក់និងចំណាយរបស់ខ្លួនដើម្បីឱ្យអាជ្ញាធរអាចពិនិត្យនិងតាមដានបញ្ជីថ្លៃលក់ និងកំណត់ថាតើចាំបាច់ត្រូវធ្វើការកែសម្រួលឬទេ។ ក្នុងការកំណត់ពេលវេលាផ្តល់ទិន្នន័យទាំងនោះឯកសារដែលត្រូវផ្តល់ឱ្យ និងបែបបទផ្សេងៗ ត្រូវអនុវត្តតាមការកំណត់ដែលមានក្នុងនីតិវិធីសម្រាប់ការតាមដានទិន្នន័យការដាក់ពាក្យស្នើសុំការពិនិត្យមើលឡើងវិញ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនីដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់។

២. បន្ទាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាពិនិត្យលើទិន្នន័យដែលបានផ្តល់រួច នៅកន្លែងណាដែលអាជ្ញាធរកំណត់ថាបញ្ជីថ្លៃលក់មានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណណាមួយចាំបាច់ត្រូវពិនិត្យឡើងវិញ ពេលនោះអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណនោះផ្តល់ពត៌មានបន្ថែមមកអាជ្ញាធរអគ្គិសនីកម្ពុជាដែលរួមមានពត៌មានហិរញ្ញវត្ថុនិងពត៌មានដទៃទៀតដែលចាំបាច់សម្រាប់អាជ្ញាធរកំណត់ថាតើចាំបាច់ត្រូវកែសម្រួលបញ្ជីថ្លៃលក់ឬទេ។ ក្នុងការកំណត់ពេលវេលាផ្តល់ទិន្នន័យទាំងនោះ ឯកសារដែលត្រូវផ្តល់ឱ្យ និងបែបបទផ្សេងៗ ត្រូវអនុវត្តតាមការកំណត់ដែលមានក្នុងនីតិវិធីសម្រាប់ការតាមដានទិន្នន័យ ការដាក់ពាក្យស្នើសុំ ការពិនិត្យមើលឡើងវិញ និងកំណត់បញ្ជីថ្លៃលក់អគ្គិសនី ដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ជាបន្តបន្ទាប់។

## ៤.២-ការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនីតាមសំណើសុំរបស់អ្នកកាន់ អាជ្ញាប័ណ្ណ

នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណចង់កែសម្រួលបញ្ជីថ្លៃលក់ដែលមានស្រាប់របស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណនេះត្រូវដាក់ពាក្យស្នើសុំកែសម្រួលបញ្ជីថ្លៃលក់មកអាជ្ញាធរអគ្គិសនីកម្ពុជា ដោយភ្ជាប់ជាមួយនូវពត៌មានហិរញ្ញវត្ថុនិងពត៌មានផ្សេងៗទៀតដែលចាំបាច់សម្រាប់អាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ថា តើចាំបាច់ត្រូវធ្វើការកែសម្រួលបញ្ជីថ្លៃលក់ឬទេ។ ក្នុងការកំណត់ពេលវេលាផ្តល់ទិន្នន័យទាំងនោះឯកសារដែលត្រូវផ្តល់ឱ្យ និងបែបបទផ្សេងៗ ត្រូវអនុវត្តតាមការកំណត់ដែលមានក្នុងនីតិវិធីសម្រាប់ការតាមដានទិន្នន័យការដាក់ពាក្យស្នើសុំការពិនិត្យមើលឡើងវិញនិងកំណត់បញ្ជីថ្លៃលក់អគ្គិសនីដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់។

## ៤.៣-ការពិនិត្យបញ្ជីថ្លៃលក់សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណថ្មី

សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណថ្មី មុនពេលចេញអាជ្ញាប័ណ្ណ អ្នកនោះត្រូវដាក់ពាក្យស្នើសុំអនុម័តបញ្ជីថ្លៃលក់មកអាជ្ញាធរអគ្គិសនីកម្ពុជារួមជាមួយនឹងពត៌មាន ហិរញ្ញវត្ថុនិងពត៌មានផ្សេងៗទៀតដែលចាំបាច់សម្រាប់អាជ្ញាធរកំណត់ថ្លៃលក់អគ្គិសនីរបស់គេ។ ក្នុងការកំណត់ពេលវេលាផ្តល់ទិន្នន័យទាំងនោះ ឯកសារដែលត្រូវផ្តល់ឱ្យ និងបែបបទផ្សេងៗ ត្រូវអនុវត្តតាមការកំណត់ដែលមានក្នុងនីតិវិធីសម្រាប់ការតាមដានទិន្នន័យ ការដាក់ពាក្យស្នើសុំការពិនិត្យមើលឡើងវិញនិងកំណត់បញ្ជីថ្លៃលក់អគ្គិសនីដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ជាបន្តបន្ទាប់។

## ៤.៤-ភារកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណពាក់ព័ន្ធនឹងការពិនិត្យបញ្ជីថ្លៃលក់អគ្គិសនី

អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗត្រូវផ្តល់ពត៌មានមកអាជ្ញាធរអគ្គិសនីកម្ពុជា ដោយអនុលោមតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យអាជ្ញាប័ណ្ណ នីតិវិធី និងបទប្បញ្ញត្តិនេះ។ ពត៌មានដែលទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជារួមមាន :

- បញ្ជីគណនេយ្យ របាយការណ៍ ទិន្នន័យ ឯកសារ និងពត៌មានផ្សេងៗ តាមទម្រង់ណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការ
- គណនេយ្យ និងពត៌មានផ្សេងៗសម្រាប់អាជីវកម្មដោយឡែកៗ របស់អ្នកកាន់អាជ្ញាប័ណ្ណដូចជា ចំណូល ចំណាយ ប្រាក់ចំណេញ ការខាតនិង ទ្រព្យសកម្មនៃអាជីវកម្មដោយឡែកនីមួយៗដែលបានកំណត់ដោយបង្ហាញតាមទម្រង់ដែលត្រូវការនៅពេលអាជីវកម្មដោយឡែកនីមួយៗត្រូវបាន បង្កើតជាក្រុមហ៊ុនដាច់ដោយឡែក។

ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមិនបានផ្តល់ទិន្នន័យណាមួយដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវការក្នុងរយះពេលដែលបានកំណត់ទេ ហើយអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាចាំបាច់នោះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចដាក់ពិន័យដល់អ្នកកាន់អាជ្ញាប័ណ្ណនោះស្របតាមមាត្រា ៧ ចំណុច “ឋ” របស់ច្បាប់។

# ជំពូកទី ៥
# ការវាយតម្លៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ

## ៥.១. ចំណាយត្រឹមត្រូវ

១. ក្នុងការកំណត់ខ្ទង់ចំណាយណាមួយ នៃចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណជាចំណាយត្រឹមត្រូវអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុវត្តតាមគោលការណ៍ដែលមានកំណត់ក្នុងអនុក្រឹត្យ និងត្រូវពិចារណាកត្តាផ្សេងៗទៀតដែលកំណត់ក្នុងបទប្បញ្ញត្តិនេះ ។

២. អាជ្ញាធរមានបំណងកំណត់ខ្ទង់ចំណាយនីមួយៗរបស់អ្នកកាន់អាជ្ញាប័ណ្ណឱ្យមានកម្រិតទាបល្មមតែឱ្យប្រតិបត្តិការអាជីវកម្មមានប្រសិទ្ធភាពនិង ស្ថិរភាព និងល្មមតែឱ្យស្ថានភាពហិរញ្ញវត្ថុមានស្ថិរភាពយូរអង្វែងប៉ុណ្ណោះ ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់កម្រិតចំណាយមួយដែលអាច ទទួលយកបានដោយយោងតាមកម្រិតចំណាយរបស់ក្រុមហ៊ុនធ្វើសេវាកម្មប្រហាក់ប្រហែលផ្សេងទៀត សន្ទស្សន៍ប្រសិទ្ធភាព ឬតាមកម្រិត បង្កើតផលិតភាពដែលអាចសម្រេចបាន ។

## ៥.២. ការកំណត់ដោយឡែកសម្រាប់អាជីវកម្មផ្សេងៗគ្នា

ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណណាមួយមានសកម្មភាពធ្វើសេវាកម្មច្រើនជាងមួយឬមានតំបន់ធ្វើសេវាកម្មច្រើនជាងមួយអាជ្ញាធរអគ្គិសនីកម្ពុជា នឹងវាយតម្លៃចំណាយត្រឹមត្រូវដោយឡែកទៅតាមប្រភេទសេវាកម្មនិងតំបន់ធ្វើសេវាកម្មដោយឡែកទាំងនោះលើកលែងតែមានកំណត់ផ្សេងពីនេះនៅក្នុងបទប្បញ្ញត្តិ ។ អនុលោមទៅតាមច្បាប់ និងអាជ្ញាប័ណ្ណសម្រាប់គោលបំណងនៃបទប្បញ្ញត្តិនេះ ប្រភេទសេវាកម្មដោយឡែកពីគ្នា ទាំងនេះរួមមាន :

១. សេវាកម្មផលិតកម្ម

២. សេវាកម្មបញ្ជូន

៣. សេវាកម្មចែកចាយ

## ៥.៣. វិធីសាស្ត្រទូទៅសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកផលិតកម្ម

ចំណាយត្រឹមត្រូវសរុបសម្រាប់សេវាកម្មផលិតកម្មមួយត្រូវវាយតម្លៃដោយអាជ្ញាធរអគ្គិសនីកម្ពុជាតាមរយៈការពិនិត្យខ្ទង់ចំណាយសំខាន់ៗ ដែលបង្កើតជាចំណាយសរុប ។ ចំណាយផ្នែកផលិតកម្មទាំងនេះមានដូចខាងក្រោម :

- ចំណាយទិញប្រេងឥន្ធនៈសម្រាប់ផលិតកម្ម
- ចំណាយដំណើរការនិងការថែទាំផ្នែកផលិតកម្ម
- ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅផ្នែកផលិតកម្ម
- ចំណាយសម្រាប់រំលោះអចលនទ្រព្យផ្នែកផលិតកម្ម
- ប្រាក់ចំណេញសមស្របផ្នែកផលិតកម្ម
- ចំណាយប្រើប្រាស់ឥណទានផ្នែកផលិតកម្ម

អាជ្ញាធរអគ្គិសនីកម្ពុជានឹងវាយតម្លៃខ្ទង់ចំណាយត្រឹមត្រូវនីមួយៗរបស់ អ្នកកាន់អាជ្ញាប័ណ្ណស្របតាមវិធីសាស្ត្រដែលមានកំណត់ក្នុងផ្នែកនេះ ដូចខាងក្រោម ។

## ៥.៤ វិធីសាស្ត្រនានាសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកសេវាកម្មបញ្ជូន

១. ចំណាយផ្នែកសេវាកម្មបញ្ជូននិងសេវាកម្មចែកចាយគឺជាចំណាយទាក់ទងនឹងការធ្វើអាជីវកម្មខ្សែបណ្តាញ ។ ចំណាយទាំងនោះរួមមាន ចំណាយទាក់ទងនឹងប្រតិបត្តិការ និងការថែទាំប្រព័ន្ធចំណាយរំលោះពន្ធផ្សេងៗ ប្រាក់ចំណេញត្រឹមត្រូវពីមូលធនផ្ទាល់ជាក់ស្តែងដែលបាន ប្រើប្រាស់ ។

២. ចំណាយត្រឹមត្រូវសរុបសម្រាប់អាជីវកម្មបញ្ជូននឹងត្រូវវាយតម្លៃដោយអាជ្ញាធរអគ្គិសនីកម្ពុជាតាមរយៈការពិនិត្យខ្ទង់ចំណាយសំខាន់ៗ ដែលបង្កើតជាចំណាយសរុបដោយប្រើប្រាស់វិធីសាស្ត្រដូចនឹងវិធីសាស្ត្រសម្រាប់ផ្នែកចែកចាយដែរ ។ អាជ្ញាធរអគ្គិសនីកម្ពុជានឹងវាយ តម្លៃខ្ទង់ចំណាយត្រឹមត្រូវនីមួយៗរបស់អ្នកកាន់អាជ្ញាប័ណ្ណស្របតាមវិធីសាស្ត្រមួយដែលមានកំណត់ខាងក្រោមនៅក្នុងផ្នែកនេះ ។

៣. នៅពេលបច្ចុប្បន្ន ចំណាយផ្នែកបញ្ជូនត្រូវគិតរួមជាមួយចំណាយផ្នែកចែកចាយ ប៉ុន្តែអាជ្ញាធរអគ្គិសនីកម្ពុជាអាចសម្រេចបែងចែកសេវាកម្មទាំងនេះនៅពេលអនាគតនិងទាមទារឱ្យផ្តល់ពត៌មានចំណាយដោយឡែកពីគ្នា ។

## ៥.៥ វិធីសាស្ត្រនានាសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃចំណាយផ្នែកសេវាកម្មចែកចាយ

ចំណាយត្រឹមត្រូវសរុបសម្រាប់អាជីវកម្មចែកចាយនឹងត្រូវវាយតម្លៃដោយអាជ្ញាធរអគ្គិសនីកម្ពុជាតាមរយៈការពិនិត្យខ្ទង់ចំណាយសំខាន់ៗដែល បង្កើតជាចំណាយសរុប ។ ចំណាយផ្នែកចែកចាយទាំងនេះ រួមមាន ៖

- ចំណាយទិញថាមពលអគ្គិសនី
- ចំណាយដំណើរការនិងការថែទាំប្រព័ន្ធចែកចាយ
- ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ
- ចំណាយសម្រាប់រំលោះអចលនទ្រព្យផ្នែកចែកចាយ
- ប្រាក់ចំណេញសមស្របសម្រាប់ផ្នែកចែកចាយ
- ចំណាយប្រើប្រាស់ឥណទានសម្រាប់ផ្នែកចែកចាយ

អាជ្ញាធរអគ្គិសនីកម្ពុជានឹងវាយតម្លៃខ្ទង់ចំណាយត្រឹមត្រូវនីមួយៗរបស់អ្នកកាន់អាជ្ញាប័ណ្ណស្របតាមវិធីសាស្ត្រដូចមានកំណត់ខាងក្រោមនៅក្នុងផ្នែកនេះ ។

## ៥.៦ គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយដំណើរការ និងការថែទាំ

១. ក្នុងការកំណត់ថាតើចំណាយដំណើរការនិងការថែទាំរបស់អ្នកកាន់អាជ្ញាប័ណ្ណណាមួយមានលក្ខណៈត្រឹមត្រូវឬទេ អាជ្ញាធរអគ្គិសនីកម្ពុជាអាចយកមកពិចារណាផងដែរនូវចំណុចខាងក្រោមនេះ ៖

(ក) និន្នាការអតិផរណាជាទូទៅ សន្ទស្សន៍ថ្លៃជាក់លាក់ និងកត្តាផ្សេងទៀតដែលប៉ះពាល់ដល់ចំណាយពិតប្រាកដរបស់អ្នកកាន់អាជ្ញាប័ណ្ណ

(ខ) គម្រោងកែលំអប្រសិទ្ធភាពនៃប្រតិបត្តិការដែលផ្តល់ដោយអ្នកកាន់អាជ្ញាប័ណ្ណជំហាននៃការអនុវត្តន៍គម្រោង និងលទ្ធផលដែលអាចសម្រេចបាន ។

២. អាជ្ញាធរអគ្គិសនីកម្ពុជារំពឹងថា អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗនឹងខិតខំកាត់បន្ថយកម្រិតចំណាយរបស់ខ្លួនឱ្យស្របតាមកម្រិតចំណាយដែលអាចទទួលយកបានមួយហើយពេលនោះកម្រិតចំណាយក្នុង១ឯកតា និងត្រូវកាត់បន្ថយជាបណ្តើរៗដែរ ។

៣. ចំណាយលើបុគ្គលិក គឺជាខ្ទង់ចំណាយមួយធំនៃចំណាយដំណើរការនិងការថែទាំរបស់អ្នកកាន់អាជ្ញាប័ណ្ណហើយអាជ្ញាធរអគ្គិសនីកម្ពុជា នឹងពិនិត្យចំនួនបុគ្គលិក អត្រាបៀវត្សនិង អត្ថប្រយោជន៍ផ្សេងៗដែលបុគ្គលិកទទួលដើម្បីធានាថាចំណាយដែលកើតឡើងនោះត្រឹមត្រូវគ្រប់ កាលៈទេសៈទាំងអស់។

៤. ចំណាយដំណើរការនិងការថែទាំអចលនទ្រព្យដែលបានជួល នឹងត្រូវចាត់ទុកថាជាចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណជាអ្នកទទួលខុសត្រូវលើការចំណាយនេះហើយអាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យថាត្រឹមត្រូវ។

## ៥.៧. គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយលើប្រេងឥន្ធនៈ

១. អាជ្ញាធរអគ្គិសនីកម្ពុជាសង្ឃឹមថាអ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ នឹងអនុវត្តការទិញប្រេងឥន្ធនៈទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអនុក្រឹត្យ។ អាជ្ញាធរអគ្គិសនីកម្ពុជាចង់ឱ្យមានការធានាថា ប្រេងឥន្ធនៈដែលមានគុណភាពត្រឹមត្រូវ ត្រូវបានទិញក្នុងតម្លៃមួយសមស្រប។ ចំពោះអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំ អាជ្ញាធរអគ្គិសនីកម្ពុជាសង្ឃឹមថាអ្នកកាន់អាជ្ញាប័ណ្ណនីមួយៗនឹងអនុវត្តដំណើរការទិញប្រេងឥន្ធនៈ តាមរយៈការដាក់ដេញថ្លៃប្រកួតប្រជែង។

២. អាជ្ញាធរអគ្គិសនីកម្ពុជាចង់ឱ្យមានការធានាថាអ្នកកាន់អាជ្ញាប័ណ្ណនឹងធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើងដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ ប្រេងឥន្ធនៈ។

## ៥.៨. គោលការណ៍កំណត់ចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ

អាជ្ញាធរអគ្គិសនីកម្ពុជាអាចពិចារណាអំពីនិន្នាការអតិផរណា សន្ទស្សន៍ថ្លៃនិងកត្តាផ្សេងៗដែលប៉ះពាល់ដល់ចំណាយពិតប្រាកដ ឬអាចកើតឡើងនៅពេលដែលអាជ្ញាធរកំណត់កម្រិតត្រឹមត្រូវនៃចំណាយរដ្ឋបាលនិងការគ្រប់គ្រងទូទៅ។

## ៥.៩. គោលការណ៍កំណត់ចំណាយត្រឹមត្រូវសម្រាប់ការទិញអគ្គិសនី

១. អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាឃើញថានីតិវិធីក្នុងការអនុវត្តការបែងចែកថាមពលអគ្គិសនីពីរោងចក្រអគ្គិសនីផ្ទាល់របស់ខ្លួន និងរោងចក្រអគ្គិសនីដែលខ្លួនបានចុះកិច្ច សន្យាជាមួយគឺបានគោរពទៅតាមគោលការណ៍លំដាប់អាទិភាពធម្មតារបស់រោងចក្រ អគ្គិសនីដែលមានថ្លៃទាប។ នីតិវិធីបែបនេះនឹងធានាថាការបំពេញតំរូវការថាមពលអគ្គិសនី នឹងមានថ្លៃសរុបទាបជាងគេដោយគិតអំពី ចំណាយសម្រាប់ប្រតិបត្តិការ ល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ការធានាស្ថិរភាពប្រព័ន្ធផលប៉ះពាល់តាមរដូវនិងល័ក្ខខ័ណ្ឌសំខាន់ៗដ៏ទៃទៀត។

២. នៅពេលណាដែលមានការចាំបាច់ត្រូវទិញអគ្គិសនីថ្មីណាមួយ

(ក) ជំហានដំបូងនៅក្នុងនីតិវិធីលទ្ធកម្មដោយការប្រកួតប្រជែង គឺការព្យាករណ៍មើលតម្រូវការថាមពលដោយអ្នកកាន់អាជ្ញាប័ណ្ណដែលក្នុងនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើការប៉ាន់ស្មានតម្រូវការប្រើប្រាស់អគ្គិសនីសម្រាប់ពេលអនាគត។ ការព្យាករណ៍នេះត្រូវគិតអំពីអត្រាកំណើនតម្រូវការផែនការកាត់បន្ថយការបាត់បង់លើបណ្តាញចែកចាយ និងពត៌មានពាក់ព័ន្ធនឹងការបន្ថែមបន្ទុកក្នុងប្រព័ន្ធរបស់អ្នកកាន់អាជ្ញាប័ណ្ណ។

(ខ) បន្ទាប់មកអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំផែនការដើម្បីបំពេញកំណើនតម្រូវការថាមពលក្នុងតំបន់ផ្គត់ផ្គង់របស់ខ្លួនដោយពិនិត្យមើលប្រភពថាមពលទាំងអស់ដែលមាន ឧទាហរណ៍ផលិតកម្មផ្ទាល់របស់ខ្លួន ការទិញអគ្គិសនីពីផលិតករអគ្គិសនីឯករាជដែលមាន ស្រាប់ការនាំចូលពីប្រទេសជិតខាង។ ការព្យាករណ៍តម្រូវការ និងផែនការលទ្ធកម្មថាមពលអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា។

(គ) មុនចុះកិច្ចព្រមព្រៀងទិញអគ្គិសនីពីផលិតករអគ្គិសនីឯករាជណាមួយ ឬទិញពីប្រភពណាផ្សេងទៀត អ្នកកាន់អាជ្ញាប័ណ្ណត្រូវបង្ហាញថា មានការចាំបាច់ត្រូវទិញថាមពលបន្ថែមហើយការទិញដែលស្នើសុំនេះគឺជាជម្រើសប្រសើរជាងគេ (ថ្លៃទាបជាងគេ) ក្នុងចំណោមប្រភពថាមពលទាំងអស់ដែលមាន។ ប្រសិនបើប្រភពថាមពលដែលមាននោះគ្មានប្រសិទ្ធភាពសេដ្ឋកិច្ច ឬមិនគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការថាមពលជម្រើសមួយក្នុងចំណោមជម្រើសផ្សេងៗទៀត គឺការដាក់ដេញថ្លៃ ប្រកួតប្រជែងលើការបង្កើតរោងចក្រអគ្គិសនីថ្មី។ ប្រសិនបើដំណើរការដេញថ្លៃប្រកួតប្រជែងធ្វើឡើងដោយមានតម្លាភាពក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដំណើរការនោះសង្ឃឹមថានឹងទទួលបានថ្លៃដើមទាប និងទទួលបានថាមពលអគ្គិសនីដែលមានស្ថិរភាព និងរស់រវើក។ ក្នុងដំណើរការនេះអាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យមើលល័ក្ខខ័ណ្ឌសេចក្តីព្រាង និងឯកសារកិច្ចព្រមព្រៀងទិញលក់ថាមពលអគ្គិសនីចុងក្រោយនិងផលប៉ះពាល់លើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអគ្គិសនីនិងអតិថិជនទាំងក្នុងរយៈពេលខ្លីនិង រយៈពេលវែង។អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាជាមុនលើថ្លៃនិងល័ក្ខខ័ណ្ឌនៃការទិញអគ្គិសនីដោយអនុលោមតាមបទប្បញ្ញត្តិ និងអាជ្ញាប័ណ្ណមុនចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញ–លក់អគ្គិសនីជាមួយភាគីមួយទៀត។

## ៥.១០ គោលការណ៍កំណត់តម្លៃត្រឹមត្រូវនៃអចលនទ្រព្យ

អនុលោមតាមអនុក្រឹត្យការកំណត់តម្លៃប្រភេទទ្រព្យសកម្មនិងមូលធនផ្សេងៗរបស់អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តតាមគោលការណ៍មូលដ្ឋានដូចខាង ក្រោម៖

១. តម្លៃដើមនៃអចលនទ្រព្យដែលអ្នកកាន់អាជ្ញាប័ណ្ណប្រើប្រាស់ក្នុងអាជីវកម្ម ត្រូវតែជាតម្លៃពិតប្រាកដនៅពេលទិញបូកបន្ថែមនូវចំណាយបន្ត បន្ទាប់ក្នុងការកែលម្អវា និងដកចេញនូវថ្លៃ ផ្នែកណាមួយនៃអចលនទ្រព្យដែលបានលក់ចេញឬឈប់ប្រើប្រាស់។ ចំណាយរបស់អ្នកកាន់អាជ្ញាប័ណ្ណត្រូវចាត់ទុកថាជា ចំណាយលើការកែលម្អអចលនទ្រព្យ ប្រសិនបើចំណាយនោះជាចំណាយដូចខាងក្រោម៖

(ក) ការពន្យារអាយុកាលអចលនទ្រព្យក្រោយអាយុ ដែលបានសន្មត់នៅក្នុងអត្រារំលោះដែលអនុវត្តចំពោះអចលនទ្រព្យនោះ ក្នុងករណីនេះអាយុកាលដែលត្រូវ រំលោះនៃអចលនទ្រព្យក៏ត្រូវកែតម្រូវឡើងវិញឱ្យសមស្របផងដែរ ឬ

(ខ) ការកែលម្អបង្កើនសមត្ថភាពមធ្យោបាយអគ្គិសនីលើសពីអត្រាសមត្ថភាពនៃអចលនទ្រព្យដែលបានកត់ត្រានៅពេលទទួលអចលនទ្រព្យនេះដំបូង។

២. នៅក្នុងការកំណត់តម្លៃដើមសុបនៃអចលនទ្រព្យ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវដកចេញនូវចំនួនទឹកប្រាក់វិភាគទានឬអំណោយផ្សេងៗសម្រាប់គោលបំណងកំណត់បញ្ជីថ្លៃលក់អគ្គិសនី លើកលែងតែក្នុងករណីពិសេសណាមួយ

ប៉ុណ្ណោះ។ ក្នុងករណីដែលចំនួនទឹកប្រាក់វិភាគទានឬអំណោយផ្សេងៗ ត្រូវបានដកចេញពីតម្លៃដើមសរុបនៃអចលនទ្រព្យ អាជ្ញាធរ អគ្គិសនីកម្ពុជាអាចបង្កើតខ្ទង់មូលនិធិមួយសម្រាប់ជំនួសអចលនទ្រព្យដែលហួសអាយុកាលសេដ្ឋកិច្ចដើម្បីធានាបាននូវផលប្រយោជន៍សាធារណៈ។

៣. ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណមានអចលនទ្រព្យដែលមិនបានទិញតាមគោលការណ៍លទ្ធកម្មប្រកួតប្រជែង ហើយដែល អាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាមានតម្លៃលើសពីតម្លៃនៅលើទីផ្សារ អាជ្ញាធរអគ្គិសនីកម្ពុជាអាចទាមទារឱ្យធ្វើការកែតម្រូវតម្លៃអចលនទ្រព្យបាន។ ការកែតម្រូវនោះត្រូវធ្វើឡើងដោយ កែសម្រួលតម្លៃអចលនទ្រព្យនោះដល់កម្រិតនៃតម្លៃមួយដែលអាចទិញបាន ប្រសិនបើអចលនទ្រព្យស្រដៀងគ្នាត្រូវបានទិញតាមការធ្វើលទ្ធកម្មដោយប្រកួតប្រជែង។

៤. នៅពេលណាដែលអ្នកកាន់អាជ្ញាប័ណ្ណទាមទារអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវកំណត់ចំនួនទុនចល័តមួយសមស្របដែលចាំបាច់សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ។ បញ្ហានេះត្រូវឆ្លុះបញ្ចាំងគ្រប់ករណីខាងក្រោម:

(ក) ចំនួនសមស្របដែលទូទាត់ពុំទាន់ដែលធ្លាប់កើតមាន នៅក្នុងអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណដំណើរការធ្វើអាជីវកម្មតាមបទពិសោធន៍ដ៏ល្អនៃពាណិជ្ជកម្ម

(ខ) មានសន្និធិប្រេងឥន្ធនៈ និងសម្ភារៈផ្សេងៗទៀតក្នុងកម្រិតធម្មតាដែលសមស្របសម្រាប់អ្នកកាន់អាជ្ញា-ប័ណ្ណរក្សានិងធានានូវស្ថិរភាពនិងគុណភាពសេវាដល់អ្នកប្រើប្រាស់។

(គ) មិនមានប្រាក់កក់ធានាគ្រប់គ្រាន់ពីអតិថិជន

៥. អាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យគម្រោងវិនិយោគធំៗរបស់អ្នក កាន់អាជ្ញាប័ណ្ណដើម្បីធ្វើការអនុម័តហើយដើម្បីគោលបំណងនេះអាជ្ញាធរអគ្គិសនីកម្ពុជាទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវពត៌មានលម្អិតអំពីផ្នែកបច្ចេកទេស និងផ្នែកពាណិជ្ជកម្ម។ គម្រោងវិនិយោគធំៗគឺជាគម្រោងណាដែលមានទំហំធំតាម ល័ក្ខខ័ណ្ឌហិរញ្ញវត្ថុឬតាមប៉ារ៉ាម៉ែត្ររូបវន្តនានាដូចជាទំហំ អាជីវកម្ម និងទំហំតំបន់ធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ។

## ៥.១១-គោលការណ៍កំណត់ចំណាយលើការជួល

ចំណាយលើការជួលអចលនទ្រព្យដែលអ្នកកាន់អាជ្ញាប័ណ្ណបានជួល ត្រូវតែអនុវត្តតាមកិច្ចព្រមព្រៀងជួលអចលនទ្រព្យដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យ និងយល់ថាត្រឹមត្រូវ។

## ៥.១២-គោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយសម្រាប់រំលោះ

១. ចំណាយសម្រាប់រំលោះអចលនទ្រព្យត្រូវកំណត់ដោយឈរលើ គោលការណ៍ ដូចខាងក្រោម:

(ក) ត្រូវប្រើប្រាស់វិធីរំលោះស្មើភាគ

(ខ) ពុំអនុញ្ញាតឱ្យមានតម្លៃនៅសល់ និង

(គ) លើកលែងតែក្នុងករណីក្នុងវាក្យខ័ណ្ឌ (ង) នៃផ្នែកនេះ អាយុកាលនៃរំលោះសម្រាប់អចលនទ្រព្យឬក្រុមអចលនទ្រព្យណាមួយត្រូវកំណត់ដោយឈរលើមូលដ្ឋាននៃការប៉ាន់ស្មានអាយុកាលប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនៃអចលនទ្រព្យនោះដូចដែលមានបង្ហាញក្នុងតារាងខាងក្រោម:

| ឈ្មោះអចលនវត្ថុ | អាយុកាល រំលោះ (ឆ្នាំ) |
|---|---|
| ដីធ្លី | មិនគិតរំលោះ |
| ការកែលម្អដីធ្លី | ៥ ឆ្នាំ |
| អគារ : | |
| -រដ្ឋបាល | ៣៣ ឆ្នាំ |
| -ផលិតកម្ម | ២៥ ឆ្នាំ |
| -បញ្ជូននិងចែកចាយ | ២៥ ឆ្នាំ |
| ឧបករណ៍ផលិតកម្មអគ្គិសនី : | |
| -ស្ថានីយ៍វារីអគ្គិសនី | ៣០ ឆ្នាំ |
| -រោងចក្រអគ្គិសនីដើរដោយប្រេងម៉ាស៊ូតសែលនិងហ្គាស | ១៨ ឆ្នាំ |
| -រោងចក្រអគ្គិសនីដើរដោយចំហាយ | ២៥ ឆ្នាំ |
| បណ្តាញបញ្ជូន និងបណ្តាញចែកចាយ : | |
| -ត្រង់ស្វូ និងបន្ទប់ភ្លើង | ២៥ ឆ្នាំ |
| -ខ្សែបណ្តាញនៅលើបង្គោលដែក១១៥គ.វ៉ និងលើស | ៣៥ ឆ្នាំ |
| -ខ្សែបណ្តាញនៅលើបង្គោលថ្ម១១៥គ.វ៉ និងលើស | ៣០ ឆ្នាំ |
| -ខ្សែបណ្តាញនៅលើបង្គោលឈើ១១៥គ.វ៉ និងក្រោម | ២៥ ឆ្នាំ |
| -នាឡិកាស្ទង់ | ១៥ ឆ្នាំ |
| -សម្ភារៈបណ្តាញផ្សេងៗ | ២៥ ឆ្នាំ |
| ផ្សេងៗ : | |
| -សម្ភារៈឧបករណ៍ការិយាល័យ | ៥ ឆ្នាំ |
| -គ្រឿងសង្ហារឹម | ១០ ឆ្នាំ |
| -មធ្យោបាយដឹកជញ្ជូន | ៦.៥ ឆ្នាំ |

(ឃ) ចំពោះអចលនវត្ថុដែលទិញក្នុងស្ថានភាពជំនំ និង អចលនវត្ថុដែលមិនមានកំណត់នៅក្នុងតារាងខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់អាយុកាលរំលោះ សម្រាប់ករណីនីមួយៗដោយពិនិត្យមើលពីស្ថានភាព អាយុ និងលក្ខខ័ណ្ឌនៃអចលនវត្ថុនោះ។

(ង) នៅក្នុងស្ថានភាពដែលមានចែងក្នុងអនុក្រឹត្យ ប្រសិនបើមានការស្នើសុំពីអ្នកកាន់អាជ្ញាប័ណ្ណ និងប្រសិនបើ

អាជ្ញាធរអគ្គិសនីកម្ពុជា យល់ព្រមអនុម័តឱ្យពេលនោះអាយុកាលរំលោះផ្សេងពីការកំណត់ខាងលើអាចអនុញ្ញាតឱ្យប្រើប្រាស់បាន ។

## ៥.១៣. គោលការណ៍កំណត់អត្រាប្រាក់ចំណេញសមស្របនិងចំណាយប្រើប្រាស់ឥណទាន

១. ក្នុងការកំណត់ថា តើអត្រាប្រាក់ចំណេញត្រូវមានកម្រិតណា ក្នុងស្ថានភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចគិតពិចារណាទៅតាមល័ក្ខខ័ណ្ឌជាក់ស្តែងពាក់ព័ន្ធនឹងអ្នកកាន់អាជ្ញាប័ណ្ណឬពាក់ព័ន្ធនឹងល័ក្ខខ័ណ្ឌអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផ្សេងពីនេះដែលខ្លួនគិតថាមានការពាក់ព័ន្ធ ។ ល័ក្ខខ័ណ្ឌទាំងនេះអាចមានអត្រាប្រាក់ចំណេញដែលរកបានដោយអាជីវកម្មស្រដៀងគ្នាផ្សេងទៀត ឬដោយអាជីវកម្មផ្សេងទៀតរបស់អ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅកន្លែងផ្សេង ហើយអ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មាននេះដល់អាជ្ញាធរអគ្គិសនីកម្ពុជា ប្រសិនបើអាជ្ញាធរយល់ថាចាំបាច់ ។

២. អត្រាចំណេញកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវគិតដល់ ការពង្រីកនិងការកែលម្អអាជីវកម្មដែលអ្នកកាន់អាជ្ញាប័ណ្ណមានកាតព្វកិច្ចអនុវត្តចំពោះអ្នកប្រើប្រាស់និងអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវធានាថាផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងផលប្រយោជន៍របស់អ្នកកាន់អាជ្ញាប័ណ្ណរក្សាបាននូវតុល្យភាពដ៏ សមស្របមួយ ។

៣. ក្នុងការកំណត់ភាពត្រឹមត្រូវនៃចំណាយប្រើប្រាស់ឥណទាន អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវគិតដល់ចំណាយប្រើប្រាស់ឥណទានដែលខ្ចីពីធនាគារ និងស្ថាប័នផ្សេង ចំណាយប្រើប្រាស់ឥណទាន ដែលខ្ចីពីអ្នកកាន់អាជ្ញាប័ណ្ណផ្សេងនិងក្រុមហ៊ុនអាជីវកម្មផ្សេង រួមទាំងអាជីវកម្មផ្សេងរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មាននេះដល់អាជ្ញាធរអគ្គិសនីកម្ពុជា នៅពេល អាជ្ញាធរអគ្គិសនីកម្ពុជាយល់ថាចាំបាច់ ។

៤. ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានឥណទានដែលចំនួននោះសមាមាត្រនឹងអចលនទ្រព្យ ហើយល័ក្ខខ័ណ្ឌទូទាត់ឥណទានទាំងនោះមានរយៈពេលខ្លី បើប្រៀបធៀបទៅនឹងអាយុកាលរំលោះនៃ អចលនទ្រព្យអ្នកកាន់អាជ្ញាប័ណ្ណអាចស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាកែសម្រួលអាយុកាលរំលោះស្របតាមចំណុច៥.១២(ង)។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវយល់ព្រមលើការផ្លាស់ប្តូរអាយុកាលរំលោះតែក្នុងករណីដែលជឿជាក់ថាអ្នកកាន់អាជ្ញាប័ណ្ណនឹងជួបការលំបាកផ្នែកចរន្តសាច់ប្រាក់ដែលនឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថិរភាពហិរញ្ញវត្ថុអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

## ៥.១៤. គោលការណ៍កំណត់ថាមពលលក់ និងចំណូល

១. អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មធុនធំត្រូវព្យាករណ៍ចំនួនអ្នកប្រើប្រាស់ និងបរិមាណថាមពលលក់ ក្នុងកំឡុងពេលពិចារណាថ្លៃលក់អគ្គិសនី ។ អាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យការប៉ាន់ស្មាន របស់អ្នកកាន់អាជ្ញាប័ណ្ណដើម្បីរកភាពត្រឹមត្រូវនិន្នាការកន្លងមក ។ល។ មុនពេលទទួលយក និងអនុម័ត ។

២. អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ត្រូវផ្តល់ពត៌មានអំពីអ្នកប្រើប្រាស់ដែលមានពត៌មានអំពីឈ្មោះថាមពលប្រើប្រាស់ចំណូលតាមវិក្កយបត្រ ។ល។ ដើម្បីសម្រួលដល់ការកំណត់ថាមពលលក់និងចំណូលឱ្យបានត្រឹមត្រូវតាមការទាមទាររបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

## ៥.១៥. គោលការណ៍កំណត់ថាមពលបាត់បង់

១. អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើការប៉ាន់ស្មានថាមពលបាត់បង់ឱ្យបានត្រឹមត្រូវតាមទម្រង់របស់អាជ្ញាធរអគ្គិសនីកម្ពុជាដើម្បី

កំណត់ការបាត់បង់ប៉ាន់ស្មានដែលអាចទទួលយកបាន។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវអនុម័តការបាត់បង់មួយដោយផ្អែកលើកម្រិតបាត់បង់ដំបូងការស្នើសុំរបស់អ្នកអាជ្ញាប័ណ្ណ ការផ្ដល់ពត៌មាន និង ការមិនព្រមរបស់អ្នកពាក់ព័ន្ធនានា។

២. ការបាត់បង់ត្រូវកាត់បន្ថយជាបណ្ដើរៗរហូតដល់កម្រិតប្រសិទ្ធភាពដែលអាចទទួលយកបាន។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ដល់គម្រោងផែនការកាត់បន្ថយការបាត់បង់ថាមពលរួមទាំងពត៌មានលម្អិតអំពីការវិនិយោគទាក់ទងនឹងការផែនការកាត់បន្ថយការបាត់បង់ថាមពលនោះ។